# ពិធីធ្វើកុសលផ្សេងៗក្នុងថ្ងៃចូលឆ្នាំ

ចាប់តាំងពីថ្ងៃចូលឆ្នាំ រហូតដល់ថ្ងៃឆថ ឧបាសក ឧបាសិកា ប្រដាប់ដោយសំលៀកបំពាក់ស អាស្រ័យនៅក្នុងវត្តហើយសមទានសីលមានសីល ៥, សីល៨, សីល ១០, ជានិច្ច ។

នៅដេពលយប់ចាស់ៗ ក្មេងក្មាង ក្រមុំ កំលោះនាំគ្នាទៅកាន់វត្តអារាម ។ ក្នុងដៃគេម្នាក់ ៗ ខ្លះមានគ្រឿងបូជាផ្សេងៗ មានទៀន ធូប ផ្កាភ្ញី ដើម្បីយកទៅប្រគេនព្រះសង្ឃ និង បូជាព្រះពុទ្ធរូប ។ លុះបានមកជួបជុំគ្នាហើយ អាចារ្យក៏ចាប់ផ្តើមនមស្សការ សមាទាសីល និមន្តព្រះសង្ឃចំរើនព្រះបរិត្តរួចនិមន្តធម្មកថិកសំដែងធម៌ទេសនា ។ ព្រឹកឡើងគេទាំងអស់គ្នាបានប្រគេនយាគូចំបោះព្រះសង្ឃ ។ ពេលថ្ងៃត្រង់ក៏បានយកចង្ហាន់មកពីផ្ទះរៀងៗខ្លួន ហើយរាប់បាត្រ បង្សុកូលដើម្បីឧទ្ទិសកុសល ជូនចំពោះជីឌូន ជីតា មាតាបិតា ស្វាមីភរិយា បងប្អូនកូនចៅញាតិមិត្តសាច់សាលោហិត និងបព្វបុរសខ្មែរទាំងឡាយដែលបានចែងឋានពីលោកនេះទៅកាន់លោកខាងមុខហើយ ។ គេម្នាក់ៗបានធ្វើរបៀបនេះជារៀងរាល់ថ្ងៃ រហូតដល់ថ្ងៃឆ្លងចូលឆ្នាំ ។ ប៉ុន្តែនៅថ្ងៃឆ្លងមានភាពអូអរ ឱឡារិកអធិកអធមជាងថ្ងៃមុនៗ។